## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់ផ្ទៃបឹងសំរោង ស្ថិតក្នុងឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៧ ស្តីពី ការបង្កើតគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួរ ក្នុងព្រះរាជាណាចក្រកម្ពុជា
- យោងស្មារតីអង្គប្រជុំរបស់គណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួរ ក្នុងព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨
- បានឃើញការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានកំណត់ផ្ទៃបឹងសំរោង ស្ថិតក្នុងឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ មានផ្ទៃសរុបចំនួន ៣៣៦ ហិកតា ( តាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រ Geocraphical Position System, GPS DATUM : INDIAN-THAILAND 1960 ) រួមមាន ៤៨ ចំណុច ដូចខាងក្រោម :

| ល.រ | ចំណុច | អាប់ស៊ីស | អ័រដោនេ | ល.រ | ចំណុច | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|---|---|
| 1 | A | 482 809 | 1 292 816 | 25 | Y | 483309 | 1 289 545 |
| 2 | B | 483 712 | 1 290 708 | 26 | Z | 483 424 | 1 289 973 |
| 3 | C | 483 597 | 1 290 445 | 27 | AA | 483 302 | 1 289 975 |
| 4 | D | 483 683 | 1 290 369 | 28 | AB | 483 300 | 1 289 868 |
| 5 | E | 483 871 | 1 290 427 | 29 | AC | 483 209 | 1 289 846 |
| 6 | F | 483 991 | 1 290 267 | 30 | AD | 483 150 | 1 290 198 |
| 7 | G | 484 115 | 1 289 950 | 31 | AE | 483 118 | 1 290 387 |
| 8 | H | 484 437 | 1 290 108 | 32 | AF | 483 282 | 1 290 480 |
| 9 | I | 484 494 | 1 290 015 | 33 | AG | 483 178 | 1 290 641 |
| 10 | J | 484 461 | 1 289 880 | 34 | AH | 482 982 | 1 290 668 |
| 11 | K | 484 175 | 1 289 793 | 35 | AI | 482 940 | 1 290 737 |
| 12 | L | 484 111 | 1 289 582 | 36 | AJ | 483 012 | 1 290 901 |
| 13 | M | 484 461 | 1 289 146 | 37 | AK | 482 839 | 1 291 583 |
| 14 | N | 484 702 | 1 289 279 | 38 | AL | 482 728 | 1 291 570 |
| 15 | O | 485 026 | 1 289 011 | 39 | AM | 482 750 | 1 29[illegible] 698 |
| 16 | P | 484 791 | 1 288 716 | 40 | AN | 482 416 | 1 291 729 |
| 17 | Q | 484 512 | 1 288 932 | 41 | AO | 482 192 | 1 292 086 |
| 18 | R | 484 456 | 1 288 827 | 42 | AP | 482 197 | 1 292 381 |
| 19 | S | 484 175 | 1 288 790 | 43 | AQ | 482 219 | 1 292 516 |
| 20 | T | 484 228 | 1 288 497 | 44 | AR | 482 411 | 1 292 835 |
| 21 | U | 484 044 | 1 288 581 | 45 | AS | 482 397 | 1 292 950 |
| 22 | V | 483 944 | 1 288 701 | 46 | AT | 482 491 | 1 292 964 |
| 23 | W | 483 958 | 1 289 004 | 47 | AU | 482 817 | 1 293 022 |
| 24 | X | 483 628 | 1 289 055 | 48 | AV | 482 891 | 1 293 012 |

**មាត្រា ២ :** ផែនទីបង្ហាញទីតាំងបឹងសំពោង ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួរ ក្នុងព្រះរាជាណាចក្រកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ